ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 20-Nov-2015, 13:46
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ មេធាវីការពារក្ដីរបស់ មាស មុត

ដាក់ជូន៖ អង្គជំនុំជម្រះតុលាការកំពូល

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយ ក.ស.ច.ស ឬ អង្គជំនុំជម្រះ៖ **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

# សំណើជាថ្មីរបស់ មាស មុត សុំធ្វើអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្ដឹងសាទុក្ខ នៅក្នុងរឿងក្ដី ០០២/០២ ក្នុងគោលបំណងពោលប្រាស្រ័យអំពី ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក.

**ឬ ម្យ៉ាងទៀត**

# សំណើជាថ្មីសុំការអនុញ្ញាតដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្ដី* ស្ដីពី ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III

---

**ដាក់ដោយ៖**

**សហមេធាវី៖**

អាង ឧត្ដម

Michael G. KARNAVAS

**ផ្ញើជូន៖**

**ចៅក្រមអង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ីម

ចៅក្រម សោម សិរិវឌ្ឍ

ចៅក្រម Agniezska KLONOWIECKA-MILART

01173397

F31

០០២/១៩-០៩-២០០៧ អ.វ.ត.ក/អ.ជ.ត.ក

ចៅក្រម ម៉ុង មុន្នីចរិយា

ចៅក្រម Chandra Nihal JAYASINGHE

ចៅក្រម  យ៉ា ណារិន

ចៅក្រម Florence Ndepele Mwachande MUMBA

**សហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Nicholas KOUMJIAN

**ក្រុមមេធាវីការពារក្តីទាំងអស់**

**ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**សំណើជាថ្មីរបស់ មាស មុត សុំធ្វើអន្តរាគមន៍ ឬ សុំការអនុញ្ញាតដាក់សារណារបស់**

***អ្នកមិនមែនជាភាគីនៃរឿងក្តី*** **ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III**

# សំណើជាថ្មីរបស់ មាស មុត សុំធ្វើអន្តរាគមន៍នៅក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅក្នុង រឿងក្តី ០០២/០១ ក្នុងគោលបំណងពោលប្រាស្រ័យអំពី អាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក.

# ឬ មួយវិញទៀត

# សំណើជាថ្មីសុំការអនុញ្ញាតដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ស្តីពី ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III

លោក មាស មុត តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") តាមរយៈនេះ ដាក់សំណើជាថ្មីសុំធ្វើអន្តរាគមន៍ ដោយផ្ទាល់មាត់ និង ជាលាយលក្ខណ៍អក្សរ នៅក្នុងបញ្ហាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០១ ដែលក្នុងនោះសហព្រះរាជអាជ្ញាប្តឹងសាទុក្ខសាលក្រមរឿងក្តី ០០២/០១ នៅលើមូលដ្ឋានថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសនៅក្នុងការមិនពិចារណាលើទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម ("សហឧក្រិដ្ឋកម្មរួមទម្រង់ទី III")[1]។ សំណើជាថ្មីនេះត្រូវបានធ្វើឡើងជាចាំបាច់ ពីព្រោះមានការផ្លាស់ប្តូរកាលៈទេសៈនៅក្នុងរឿងក្តី ០០២/០១។

## I. សាវតារ

១. នៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ អង្គជំនុំជម្រះតុលាការកំពូលបានបង្គាប់ឲ្យតែងតាំងមេធាវីការពារក្តីប្រចាំការឲ្យតំណាងក្តីឲ្យលោក នួន ជា នៅក្នុងសវនាការលើបណ្តឹងសាទុក្ខរឿងក្តី ០០២/០១។ នៅក្នុងសវនាការថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ លោក នួន ជា បានចង្អុលបង្ហាញថា គាត់បានបង្គាប់ឲ្យ *សហមេធាវីរបស់គាត់មិនចូលរួមនៅក្នុងសវនាការលើបណ្តឹងសាទុក្ខ និង* មិនឆ្លើយតបទៅនឹងសំណួរណាមួយរបស់ចៅក្រម ឬ ភាគីផ្សេងទៀត[2]។ អនុលោមតាមការបង្គាប់

[1] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០២/០១ ចុះថ្ងៃទី ២៨ ខែវិច្ឆិកា ឆ្នាំ ២០១៤ ឯកសារ F11។

[2] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ការឆ្លើយតបរបស់មេធាវីជាតិ លោក សុន អរុណ ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីហេតុការណ៍ដែលបានកើតឡើងនៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ F30/13 កថាខណ្ឌ ៣។

របស់លោក នួន ជា សហមេធាវីអន្តរជាតិរបស់លោក នួន ជា មិនបានចូលរួមនៅក្នុងសវនាការលើបណ្តឹងសាទុក្ខឡើយ។ សហមេធាវីជាតិរបស់គាត់មានវត្តមាន ប៉ុន្តែបានចង្អុលបង្ហាញថា គាត់ត្រូវបានបង្គាប់មិនឲ្យចូលរួម ឬ ឆ្លើយតបនឹងសំណួរណាមួយ[3]។ លោក នួន ជា បានចង្អុលបង្ហាញថា គាត់ និង សហមេធាវីរបស់គាត់រក្សាទុកនូវទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន[4]។

២. អង្គជំនុំជម្រះតុលាការកំពូលបានផ្អាកសវនាការលើបណ្តឹងសាទុក្ខ។ អង្គជំនុំជម្រះបានសម្រេចថា ចរិតលក្ខណៈនៃសវនាការលើបណ្តឹងសាទុក្ខមិនអនុញ្ញាតឲ្យលោក នួន ជា លះបង់សិទ្ធិរបស់គាត់តំណាងក្តីដោយមេធាវីការពារក្តីឡើយ ហើយថា មេធាវីការពារក្តីត្រូវតែមានវត្តមាន និង បានបង្គាប់ឲ្យតែងតាំងមេធាវីការពារក្តីប្រចាំការ[5]។

## II. សំណើ

៣. ហេតុការណ៍នៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ បានបណ្តាលឲ្យមានការផ្លាស់ប្តូរកាលៈទេសៈនៅក្នុងរឿងក្តី 00២/0១ ដែលធានាឲ្យទទួលបានការអនុញ្ញាតតាមសំណើនេះ។ ទោះបីជាអង្គជំនុំជម្រះតុលាការកំពូល ពីមុនធ្លាប់បានបដិសេធសំណើស្រដៀងគ្នានេះរបស់មេធាវីការពារក្តីក៏ដោយ[6] ក៏អង្គជំនុំជម្រះអាចពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងករណីដែលមានមូលដ្ឋានស្របច្បាប់ ដូចជាការផ្លាស់ប្តូរកាលៈទេសៈ (រួមទាំងអង្គហេតុ ឬ ទឡ្ហីករណ៍ថ្មី) ជាដើម

---

[3] *ដូចខាងលើ* កថាខណ្ឌ ២-៣។

[4] *ដូចខាងលើ* កថាខណ្ឌ ៣។

[5] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ 00២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ (លេខឯកសារមិនមានជាសាធារណៈ។ ពង្រាងនៃប្រតិចារឹកមិនមានជាសាធារណៈ)។ *សូមមើលផងដែរ* Anthony Jensen *មេធាវីការពារក្តីរបស់ នួន ជា សំដែងការដើរចេញនៅសាលាក្តី* (Nuon Chea's Defence Stages Walkout at Tribunal) សារព័ត៌មានខេមបូឌាដេលី ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៥។

[6] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ 00២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្តីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង 00២/0១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ F20/1។

ឬ ក្នុងករណីដែលខ្លួនដឹងថា សេចក្ដីសម្រេចពីមុនគឺមានកំហុស ឬ បានបណ្ដាលឱ្យមានភាពអយុត្តិធម៌[7]។

៤. ការផ្លាស់ប្ដូរកាលៈទេសៈនៅក្នុងរឿងក្ដី ០០២/០១ សមនឹងឱ្យមេធាវីការពារក្ដីទទួលបានការអនុញ្ញាតឱ្យធ្វើអន្តរាគមន៍ដើម្បីជាប្រយោជន៍យុត្តិធម៌[8]។ សហមេធាវីជាតិរបស់លោក នួន ជា បានចង្អុលបង្ហាញថា ក្រុមរបស់គាត់នឹងមិនធ្វើសំណើសុំការពិចារណាបន្ថែមទៀតលើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ឡើយ ព្រោះថា ពួកគេរក្សានូវអ្វីដែលមាននៅក្នុងបណ្ដឹងសាទុក្ខរបស់ខ្លួន[9]។ មេធាវីការពារក្ដីប្រចាំការរបស់លោក នួន ជា គឺជាអ្នកថ្មីនៅ អ.វ.ត.ក. និងមិនស៊ាំជាមួយនឹងរឿងក្ដី ០០១ និង ០០២ និង សារណារបស់ភាគីលើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក. ឡើយ។ គ្មានការចង្អុលបង្ហាញថា តើមេធាវីការពារក្ដីប្រចាំការនឹងធ្វើសំណើសុំការពិចារណាលើបញ្ហានេះ ឬយ៉ាងណាឡើយ។ បើទោះបីជាមេធាវីការពារក្ដីប្រចាំការបានធ្វើសំណើសុំការពិចារណានេះក៏ដោយ ក៏ពួកគេអាចនឹងមិនមានមធ្យោបាយដើម្បីពោលប្រាស្រ័យឱ្យបានពេញលេញអំពីបញ្ហានេះ ដោយសារកង្វះភាពស៊ាំទៅនឹងរឿងក្ដី និងបញ្ហានេះ។ អនុញ្ញាតឱ្យមេធាវីការពារក្ដីធ្វើអន្តរាគមន៍នឹងធានាបានថា អង្គជំនុំជម្រះតុលាការកំពូលទទួលបានព័ត៌មានពេញលេញអំពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក.។

---

[7] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ០៣) សេចក្ដីសម្រេចលើពាក្យសុំឱ្យពិចារណាសារជាថ្មី លើសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯងផ្ទាល់ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ ២០០៨ ឯកសារ C22/I/68 កថាខណ្ឌ ២៥។ *រឿងក្ដី មាស មុត* សំណុំរឿងលេខ ០០៣/២៩-០៧-២០១១-អ.វ.ត.ក/អ.ប.ជ (០១) សេចក្ដីសម្រេចលើញត្តិសុំឱ្យពិចារណាឡើងវិញលើសេចក្ដីសម្រេចស្ដីពីសំណើរបស់ផ្នែកគាំពារការការពារក្ដីសុំផ្អាកកិច្ចដំណើរការនីតិវិធីក្នុងរឿងក្ដី ០០៣ នៅចំពោះមុខអង្គបុរេជំនុំជម្រះ និង សុំវិធានការទាក់ទងនឹងការតំណាងក្ដីប្រកបដោយប្រសិទ្ធភាពឱ្យជនសង្ស័យនៅក្នុងរឿងក្ដី ០០៣ ចុះថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១២ ៥ កថាខណ្ឌ ៣។

[8] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សេចក្ដីសម្រេចលើសំណើសុំធ្វើអន្តរាគមន៍ ឬ សុំដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្ដី* នៅក្នុងកិច្ចដំណើរការនីតិវិធីលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ៨ ខែមេសា ឆ្នាំ ២០១៥ ឯកសារ F20/1 កថាខណ្ឌ ១២។

[9] *រឿងក្ដី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក ការឆ្លើយតបរបស់មេធាវីជាតិ លោក សុន អរុណ ទៅនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលអំពីហេតុការណ៍ដែលបានកើតឡើងនៅថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ ចុះថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ ២០១៥ ឯកសារ F30/13 កថាខណ្ឌ ៣។

៥. ម្យ៉ាងទៀត អនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុង អ.វ.ត.ក. មេធាវី ការពារក្តីសុំការអនុញ្ញាតដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* លើបញ្ហាដែលថា តើ សហឧក្រិដ្ឋកម្មរួមទម្រង់ទី III អាចអនុវត្តបាននៅ អ.វ.ត.ក. ឬយ៉ាងណា។ មេធាវីការពារក្តីមិនមានចេតនានឹងដើរតួនាទីជាមេធាវីការពារក្តីជំនួសសម្រាប់លោក នួន ជា ឬ បំពេញបន្ថែមសំណើសុំការពិចារណាណាមួយដែលមេធាវីការពារក្តីប្រចាំការអាចធ្វើលើបញ្ហានេះឡើយ។ សារណានេះមានគោលបំណងគ្រាន់តែផ្តល់ជាជំនួយដល់អង្គជំនុំជម្រះតុលាការកំពូលលើបញ្ហានេះប៉ុណ្ណោះ[10]។ សារណានេះនឹងបង្ហាញថា សហឧក្រិដ្ឋកម្មរួមទម្រង់ទី III មិនធ្លាប់មានអត្ថិភាពជាច្បាប់ទំនៀមអន្តរជាតិនៅក្នុងឆ្នាំ ១៩៧៥-១៩៧៩ ហើយដូច្នេះ មិនគួរត្រូវបានអនុវត្តនៅ អ.វ.ត.ក. ឡើយ។

៦. ដើម្បីគាំទ្រសំណើសុំការពិចារណារបស់មេធាវីការពារក្តី ស្តីពីការធ្វើអន្តរាគមន៍នៅក្នុងរឿងក្តី ០០២/០១ ឬ ដើរតួនាទីជា *អ្នកមិនមែនជាភាគីនៃរឿងក្តី* មេធាវីការពារក្តីដាក់បញ្ចូលដោយយោងសំណើសុំការពិចារណារបស់ខ្លួនពីកថាខណ្ឌ ១ ដល់កថាខណ្ឌ ១៧ នៃសំណើរបស់មេធាវីការពារក្តី ០០៣ សុំធ្វើអន្តរាគមន៍ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងរឿងក្តី ០០២/០១ ក្នុងគោលបំណងលើកឡើងអំពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក. ឬ ម្យ៉ាងទៀត ស្នើសុំការអនុញ្ញាតដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III[11]។

---

[10] នៅក្នុងរឿងក្តី ០០១ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ភាពស្មុគស្មាញនៃបញ្ហានេះ និង បានបើកឲ្យដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី*។ នៅក្នុងរឿងក្តី ០០២ អង្គបុរេជំនុំជម្រះបានអនុញ្ញាតឲ្យភាគីពន្យារពេល និង បន្ថែមចំនួនទំព័រ ដើម្បីពោលប្រាស្រ័យអំពីបញ្ហានេះ។ *សូមមើល ឧទាហរណ៍ រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សេចក្តីអញ្ជើញ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ចុះថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ ២០០៨ ឯកសារ D99/3/12។ *រឿងក្តី កាំង ហ្គេកអ៊ាវ* សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ០២) សេចក្តីអញ្ជើញ *អ្នកដែលមិនមែនជាភាគីនៃរឿងក្តី* ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ឯកសារ D99/3/13 និង ឯកសារ D99/3/14។ *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៣៥ ៣៧ ៣៨ ៣៩) សេចក្តីសម្រេចលើសំណើសុំពន្យារពេល និង បន្ថែមចំនួនទំព័ររបស់សហព្រះរាជអាជ្ញាក្នុងការដាក់ចម្លើយតបរួមទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ អៀង ធីរិទ្ធ ខៀវ សំផន អៀង សារី និង ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនប្រឆាំងនឹងដីកាសម្រេចស្តីពីសហឧក្រិដ្ឋកម្មរួម (JCE) ចុះថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០១០ ឯកសារ D97/16/4។

[11] *រឿងក្តី នួន ជា និង អ្នកផ្សេងទៀត* សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក សំណើរបស់មេធាវីការពារក្តី ០០៣ សុំធ្វើអន្តរាគមន៍ក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខនៅក្នុងករណី ០០២/០១ ក្នុងគោលបំណងលើកឡើងអំពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III នៅ អ.វ.ត.ក. ឬ ម្យ៉ាងទៀត ស្នើសុំការអនុញ្ញាតដាក់សារណារបស់ *អ្នក*

**អាស្រ័យហេតុនេះ** យោងតាមសំអាងហេតុទាំងអស់ដែលបានលើកឡើងខាងលើ មេធាវីការពារក្តីគោរពស្នើសុំអង្គជំនុំជម្រះតុលាការកំពូល មេត្តាអនុញ្ញាតឲ្យមេធាវីការពារក្តីធ្វើអន្តរាគមន៍ ដោយផ្ទាល់មាត់ និង ជាលាយលក្ខណ៍អក្សរ នៅក្នុងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី ០០២/០១។ ម្យ៉ាងទៀត មេធាវីការពារក្តីស្នើសុំការអនុញ្ញាតដាក់សារណារបស់ *អ្នកមិនមែនជាភាគីនៃរឿងក្តី* លើបញ្ហាថាតើសហឧក្រិដ្ឋកម្មទម្រង់ទី III អាចអនុវត្តបាននៅ អ.វ.ត.ក. ឬយ៉ាងណា។

សូមលោកចៅក្រមមេត្តាទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **២០** ខែ**វិច្ឆិកា** ឆ្នាំ **២០១៥**

សហមេធាវីការពារក្តីលោក មាស មុត

________________ ________________

អាង ឧត្តម Michael G. KARNAVAS

---

*មិនមែនជាភាគីនៃរឿងក្តី* ស្តីពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី III ចុះថ្ងៃទី ១២ ខែមករា ឆ្នាំ ២០១៥ ឯកសារ F20។